# ឯកសារព័ត៌មានអំពីក្រមចំណីអាហារ #9

*ប្រការដែលអ្នកគួរយល់ដឹងអំពីក្រម*

WWW.HEALTHOREGON.ORG/
FOODSAFETY

## ឆ្កែចិញ្ចឹមនៅកន្លែងអង្គុយដែលបានកំណត់នៅខាងក្រៅ

**OAR 333-150-0000**
**ជំពូកទី 6-501.115**

(E) ឆ្កែចិញ្ចឹមអាចត្រូវបានអនុញ្ញាតឱ្យនៅកន្លែងអង្គុយនៅខាងក្រៅនៃគ្រឹះស្ថានចំណីអាហារតាមលក្ខខណ្ឌខាងក្រោម៖
(1) គ្រឹះស្ថានចំណីអាហាររៀបចំនីតិវិធីជាលាយលក្ខណ៍អក្សរដែលរួមមាន៖
(a) ដ្យាក្រាមទីកន្លែងនៅខាងក្រៅដែលត្រូវកំណត់ថាអាចប្រើបានសម្រាប់អតិថិជនដែលមានឆ្កែចិញ្ចឹម Pf
(b) នីតិវិធីរបស់គ្រឹះស្ថានសម្រាប់ការធានាថានិយោជិតមិនប៉ះ អង្អែល ឬកាន់ឆ្កែចិញ្ចឹម និងសម្រាប់ការសម្អាតភ្លាមៗនូវករណីថៃដន្យទាក់ទងនឹងលាមកឆ្កែ។ នីតិវិធីក៏ត្រូវតែរៀបរាប់ពីទីតាំងនៃសម្ភារៈ និងឧបករណ៍ចាំបាច់ដើម្បីសម្អាតករណីដែលទាក់ទងនឹងលាមកឆ្កែ Pf និង
(c) នីតិវិធីរបស់គ្រឹះស្ថានដើម្បីជូនដំណឹងដល់និយោជិត និងអតិថិជនអំពីលក្ខខណ្ឌទាមទារនៃកថាខណ្ឌនេះ។ Pf
(2) ឆ្កែចិញ្ចឹមអាចនឹងមិនប៉ះពាល់ជាមួយនឹងចាន ប្រដាប់ប្រដាប្រើប្រាស់ និងគ្រឿងសម្រាប់បរិភោគអាហារ។ ឆ្កែចិញ្ចឹមក៏មិនត្រូវបានអនុញ្ញាតឱ្យនៅលើកៅអី តុ និងគ្រឿងសង្ហារិមផ្សេងទៀតដែរ។ Pf
(3) និយោជិត និងអតិថិជនអាចនឹងមិនផ្តល់អាហារដល់ឆ្កែចិញ្ចឹម។ Pf
(4) ឆ្កែចិញ្ចឹមត្រូវតែមានខ្សែចង និងស្ថិតក្រោមការគ្រប់គ្រងរបស់អតិថិជនគ្រប់ពេលទាំងអស់។ Pf
(5) កុំឱ្យឆ្កែចិញ្ចឹមដើរកាត់ខាងក្នុង ឬផ្នែកខាងក្រៅដែលមិនបានកំណត់របស់គ្រឹះស្ថានចំណីអាហារឱ្យសោះ។ Pf

**ហេតុផលសុខភាពសាធារណៈ៖**

ក្តីកង្វល់ពីសុខភាពរួមមាន សត្វចិញ្ចឹមបន្ទោរបង់លើកម្រាល និយោជិតអង្អែលពួកវាហើយមិនលាងដៃ ឆ្កែស៊ីពីចានអតិថិជន និងមានអាកប្បកិរិយារំខាន។ នៅក្នុងការវាយតម្លៃហានិភ័យសុខភាព នាយកដ្ឋានសុខភាពសាធារណៈបានកំណត់ប្រភេទនៃកន្លែងទទួលទានអាហារនៅខាងក្រៅដែលនឹងធ្វើឱ្យមានហានិភ័យទាប តិចបំផុត ឬគ្មានហានិភ័យចំពោះសាធារណជន។ នៅកន្លែងទាំងនេះ គេតម្រូវឱ្យម្ចាស់ភោជនីយដ្ឋានដែលអនុញ្ញាតឱ្យឆ្កែនៅកន្លែងទទួលទានអាហារខាងក្រៅធ្វើតាមការអនុវត្តនានាដើម្បីកាត់បន្ថយហានិភ័យដែលអាចមានឱ្យដល់កម្រិតអប្បរមា។ មិនមានការផ្លាស់ប្តូរសម្រាប់កន្លែងទទួលទានខាងក្នុងទេ។ សត្វតែម្យ៉ាងដែលត្រូវបានអនុញ្ញាតឱ្យចូលទៅខាងក្នុងភោជនីយដ្ឋានគឺសត្វបម្រើសេវាកម្មដែលទៅជាមួយជនពិការ ឬសត្វបម្រើសេវាកម្មដូចជាឆ្កែប៉ូលិស។

បទប្បញ្ញត្តិនៃវិធានថ្មីអនុញ្ញាតឱ្យប្រតិបត្តិករសេវាកម្មចំណីអាហារផ្តល់កន្លែងអង្គុយដែលបានកំណត់នៅខាងក្រៅសម្រាប់ភ្ញៀវដែលចង់ទទួលទានអាហារជាមួយឆ្កែចិញ្ចឹមរបស់ពួកគេ។ គ្រឹះស្ថានដែលចង់ផ្តល់ការអនុញ្ញាតសម្រាប់ឆ្កែចិញ្ចឹមត្រូវតែផ្តល់នីតិវិធីជាលាយលក្ខណ៍អក្សរដែលបញ្ជាក់ពីរបៀបដោះស្រាយក្តីបារម្ភអំពីសុខភាពសាធារណៈ មុនពេលអនុញ្ញាតឱ្យឆ្កែរបស់ភ្ញៀវនៅក្នុងបរិវេណគ្រឹះស្ថាន។

ត្រូវផ្តល់ព័ត៌មានខាងក្រោម៖

1. ដ្យាក្រាម និងការពណ៌នាអំពីតំបន់ខាងក្រៅដែលកំណត់ថាជាទីកន្លែងដែលភ្ញៀវមានឆ្កែអាចប្រើបាន។
2. ភ្ជាប់ច្បាប់ចម្លងនៃគោលនយោបាយរបស់គ្រឹះស្ថានសម្រាប់និយោជិតទាំងអស់ដែលចែងថា "ហាមនិយោជិតប៉ះ អង្អែល ឬកាន់ឆ្កែនៅពេលបម្រើអាហារឬភេសជ្ជៈ កាន់គ្រឿងសម្រាប់បរិភោគអាហារ" និង "ត្រូវសម្អាតភ្លាមៗនៅពេលមានករណីថៃដន្យទាក់ទងនឹងលាមកឆ្កែ"។ គោលនយោបាយក៏ត្រូវរៀបរាប់ពីទីតាំងសម្ភារៈសម្អាតលាមកឆ្កែផងដែរ។
3. រៀបរាប់ពីវិធីសាស្ត្រនៃការជូនដំណឹងដល់និយោជិត និងភ្ញៀវរបស់គ្រឹះស្ថានសេវាកម្មចំណីអាហារដូចខាងក្រោម៖

- មិនត្រូវឱ្យឆ្កែប៉ះពាល់ជាមួយនឹងចាន ប្រដាប់ប្រដាប្រើប្រាស់ និងគ្រឿងសម្រាប់បរិភោគអាហារឡើយ។ ភ្ញៀវត្រូវចង និងមើលគ្រប់គ្រងឆ្កែគ្រប់ពេលទាំងអស់។
- មិនត្រូវឱ្យឆ្កែនៅលើកៅអី តុ ឬគ្រឿងសង្ហារិមផ្សេងទៀតឡើយ។



***អនុញ្ញាតចំពោះឆ្កែដែលមានរបៀប***

- កុំឱ្យឆ្កែដើរកាត់ខាងក្នុង ឬផ្នែកខាងក្រៅដែលមិនមានការកំណត់នៃគ្រឹះស្ថានចំណីអាហារឱ្យសោះ។ ឆ្កែបម្រើសេវាកម្ម**ត្រូវបាន**អនុញ្ញាតឱ្យនៅខាងក្នុងនៅទីកន្លែងអតិថិជន។
- ហាមឆ្កែដែលបង្កគ្រោះថ្នាក់ ឬអាចបង្កគ្រោះថ្នាក់។ គ្រឹះស្ថានចំណីអាហារអាចនឹងយកឆ្កែចេញពីបរិវេណ។



Oregon Health Authority